# ការយល់ដឹងពីប្រព័ន្ធផ្ទុកទិន្នន័យនៃអន្តរាគមន៍ទាន់ពេល

តាមរយៈការិយាល័យផ្តល់សេវាអន្តរាគមន៍ទាន់ពេល ការិយាល័យអភិវឌ្ឍន៍កុមារ និងការសិក្សារបស់កុមារតូច (OCDEL) បានបម្រើដល់កុមារ កុមារចេះដើរតេសតាស និងកុមារមិនទាន់គ្រប់អាយុចូលសាលាដែលមានការលូតលាស់យឺតយ៉ាវ និង/ឬពិការពីកំណើតរហូតដល់ពួកគេគ្រប់អាយុចូលសាលាប្រមាណជា ៧៩,០០០នាក់។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអេឡិចត្រូនិកយកមកប្រើប្រាស់ដើម្បីរក្សាទុករបាយការណ៍របស់កុមារនីមួយៗនៅក្នុងកម្មវិធីអន្តរាគមន៍ទាន់ពេល (EI)។

### *តើប្រព័ន្ធផ្ទុកទិន្នន័យនៃអន្តរាគមន៍ទាន់ពេលគឺជាអ្វី?*

**PELICAN** (សហគ្រាសតភ្ជាប់ព័ត៌មានសម្រាប់កុមារនៅក្នុងប្រព័ន្ធរបស់រដ្ឋ Pennsylvania) គឺជាឈ្មោះរបស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន OCDEL។ គេប្រើប្រាស់វាសម្រាប់គ្រប់គ្រងរាល់របាយការណ៍របស់កុមារដែលបានទទួលសេវា EI នៅក្នុងសហធនទាំងមូល។ រាល់ព័ត៌មានដែលបញ្ចូលទៅក្នុង PELICAN គឺផ្អែកទៅលើព័ត៌មានដែលក្រុមគ្រួសារផ្តល់ឲ្យអ្នកសម្របសម្រួលផ្នែកសេវាកម្ម ឬអ្នកផ្តល់សេវាអន្តរាគមន៍ទាន់ពេលអំពីកុមារ តាមរយៈការសន្ទនាគ្នា លិខិតឆ្លើយឆ្លង និងការជួបគ្នា។ ប្រព័ន្ធ PELICAN នេះរួមមាន៖

- ព័ត៌មានប្រជាសាស្ត្ររបស់កុមារដូចជា ឈ្មោះ អាសយដ្ឋាន ព័ត៌មានទំនាក់ទំនង ថ្ងៃខែឆ្នាំកំណើត ។ល។
- ព័ត៌មានស្តីពីការវាយតម្លៃ
- ព័ត៌មានស្តីពីទម្លាប់ និងសកម្មភាពរបស់ក្រុមគ្រួសារដើម្បីឲ្យ OCDEL ផ្តល់សេវាឲ្យត្រូវនឹងមជ្ឈដ្ឋានធម្មជាតិរបស់កុមារ
- ផែនការផ្តល់សេវាដល់គ្រួសារនីមួយៗ (IFSP) និងកម្មវិធីអប់រំឯកត្តភាព (IEP)
- ផែនការក្នុងការផ្លាស់ប្តូរ

ដើម្បីឲ្យប្រាកដថា កុមារនីមួយៗមានលេខកំណត់អត្តសញ្ញាណតែមួយនោះ កម្មវិធី EI នឹងសុំឲ្យក្រុមគ្រួសារផ្តល់លេខសុវត្ថិភាពសង្គមរបស់កុមារ (SSN)។ SSN របស់កុមារជានាឲ្យមានអត្តសញ្ញាណកម្មត្រឹមត្រូវនៃព័ត៌មានរបស់កុមារ ជាពិសេសក្នុងករណីដែលវាមាននៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់រដ្ឋផ្សេងរួចហើយនោះ។ វាការពារក្រុមគ្រួសារកុមារមិនឲ្យផ្តល់ព័ត៌មានដូចគ្នាច្រំដែល។ ប៉ុន្តែការផ្តល់ SSN របស់កុមារមិនចាំបាច់ចំពោះការទទួលសេវា EI ឡើយ។

### *ហេតុអ្វីបានជាព័ត៌មានត្រូវបានប្រមូលនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ?*

ព័ត៌មានកុមារត្រូវបានប្រមូលដើម្បីធ្វើឲ្យមានគណនេយ្យភាព និងការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាពដែលរួមមាន ៖

- ការវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធី EI និងសេវាកម្មក្នុងការគាំទ្រកុមារ និងក្រុមគ្រួសារទាំងនៅថ្នាក់រដ្ឋ និងតាមមូលដ្ឋាន
- ការកំណត់ពីការអនុវត្តដ៏ល្អបំផុត និងចំណុចសម្រាប់កែលម្អនៅថ្នាក់រដ្ឋ
- ការបំពេញរបាយការណ៍រដ្ឋ និងសហព័ន្ធ
- ការផ្តល់ប្រាក់កំរៃដល់អ្នកផ្តល់សេវា។

### *តើប្រព័ន្ធផ្ទុកទិន្នន័យអេឡិចត្រូនិកផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ក្រុមគ្រួសារកុមារ?*

ក្រុមគ្រួសារមិនចាំបាច់ផ្តល់ព័ត៌មានដូចគ្នាម្តងហើយម្តងទៀត នៅពេលដែលខ្លួនឆ្លងកាត់កម្មវិធី EI នោះទេ។ របាយការណ៍នីមួយៗរបស់កុមារដែលផ្ទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាននឹងត្រូវដាក់លេខកំណត់អត្តសញ្ញាណមួយ។ នេះមានន័យថា កុមារនីមួយៗដែលទទួលបានសេវានឹងមានរបាយការណ៍តែមួយប៉ុណ្ណោះនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យនៅទូទាំងរដ្ឋ ដោយមិនគិតពីរបៀបដែលពួកគេចូលទៅក្នុងប្រព័ន្ធ ឬប្រភេទសេវាដែលពួកគេបានទទួល។

ការរក្សាទុករបាយការណ៍កុមារតាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចឲ្យក្រុមការងារ IFSP/IEP របស់ពួកគេប្រើប្រាស់របាយការណ៍នោះបាន។ វាក៏អនុញ្ញាតឲ្យមានការដោះដូរព័ត៌មានដ៏រលូននៅពេលដែលកុមារផ្លាស់ប្តូរពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ព្រោះគេអាចចែករំលែករបាយការណ៍កុមារបានយ៉ាងឆាប់រហ័សជាមួយនឹងកម្មវិធីថ្មី (ដោយមានការឯកភាពពីមាតាបិតា)។

ប្រព័ន្ធផ្ទុកទិន្នន័យលើកកម្ពស់ និងធានាឲ្យមាន៖

- សេវាកម្មប្រកបដោយគុណភាពសម្រាប់កុមារ
- គណនេយ្យភាពនៃកម្មវិធីដើម្បីធានាថា គ្រប់ធនធានទាំងអស់បានយកមកប្រើប្រាស់ដ៏មានប្រសិទ្ធភាព និងឆ្លាតវៃ
- ការរំពឹងថាមានបំលាស់ប្តូរតម្រូវការ
- និរន្តរភាពនៃទិន្នន័យនៅក្នុងកម្មវិធី។

### *តើនរណាខ្លះអាចប្រើប្រាស់ព័ត៌មានរបស់កុមារបាន?*

ព័ត៌មានកុមារដែលផ្ទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានរក្សាទុកជាការសម្ងាត់ ហើយមានតែបុគ្គលដែលមានសិទ្ធិប៉ុណ្ណោះនឹងអាចប្រើប្រាស់របាយការណ៍នេះបាន ទៅតាមច្បាប់ស្តីពីការរក្សាការសម្ងាត់របស់សហព័ន្ធ និងរដ្ឋ ឯកជនភាព និងសុវត្ថិភាព។ រាល់ទិន្នន័យនៅក្នុង PELICAN ត្រូវបានការពារដោយប្រូតូកូលសុវត្ថិភាព ដែលទាមទារនូវស៊ើរវើដ៏មានប្រសិទ្ធភាពដែលបានដាក់កូដ

ឈ្មោះអ្នកប្រើប្រាស់តែមួយគត់ដែលមានលេខសម្ងាត់ប្រកបដោយសុវត្ថិភាព និងតួនាទីអ្នកប្រើប្រាស់ដែលមានតួនាទីសុវត្ថិភាព និងការចូលទៅប្រើប្រាស់ជាក់លាក់។ នេះមានន័យថា ៖

- មានតែរដ្ឋដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងកុមារណាម្នាក់ប៉ុណ្ណោះអាចប្រើប្រាស់ព័ត៌មានកុមារនេះបាន។
- មន្ត្រីរាជការអាចប្រើប្រាស់ព័ត៌មានកុមារបានដ៏មានកំរិតក្នុងគោលបំណងត្រួតពិនិត្យការផ្តល់សេវា EI។
- ព័ត៌មានរបស់កុមារនឹងមិនត្រូវបានចែករំលែកក្រៅកម្មវិធីឡើយ លើកលែងតែមានការអនុញ្ញាតដោយច្បាប់ និង/ឬមានការឯកភាពពីមាតាបិតា។
- ក្រុមគ្រួសារមានសិទ្ធិពិនិត្យមើល និងត្រួតពិនិត្យឡើងវិញលើរបាយការណ៍ EI ដែលទាក់ទិននឹងកុមារ និងស្នើសុំធ្វើការកែប្រែចំពោះព័ត៌មានដែលគ្មានសុក្រិតភាពនៅក្នុងរបាយការណ៍ណាមួយ។ ក្រុមគ្រួសារកុមារក៏អាចថតចម្លងរបាយការណ៍កុមារបានផងដែរ ទៅតាមការស្នើសុំ ហើយរក្សាទុកសម្រាប់រយៈពេលបួនឆ្នាំ។
- ដោយមានការអនុញ្ញាតពីច្បាប់ សម្រាប់គោលបំណងធ្វើការផ្លាស់ប្តូរ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងព័ត៌មានទំនាក់ទំនងមាតាបិតារបស់កុមារនឹងត្រូវចែករំលែកជាមួយនឹងកម្មវិធីអន្តរាគមន៍ទាន់ពេលសម្រាប់កុមារមិនទាន់គ្រប់អាយុចូលសាលាក្នុងឆ្នាំដែលបានផ្លាស់ប្តូរដើម្បីសម្រួលដល់ការរៀបចំផែនការ។

### *តើក្រុមគ្រួសារគួរតែទំនាក់ទំនងសាកសួរនរណាអំពីរបាយការណ៍របស់កុមារនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យទាំងនេះ?*

ក្រុមគ្រួសារកុមារគួរតែទូរស័ព្ទទំនាក់ទំនងអ្នកសម្របសម្រួលផ្នែកសេវាកម្មកុមារ គ្រូបង្រៀន/គ្រូពេទ្យព្យាបាល ឬអ្នកគ្រប់គ្រងកម្មវិធី EI សម្រាប់កុមារមិនទាន់គ្រប់អាយុចូលសាលា ប្រសិនបើពួកគេមានចម្ងល់ណាមួយទាក់ទិននឹងការប្រមូលព័ត៌មានរបស់កុមារនៅក្នុង PELICAN។ ប្រសិនបើនៅពេលណាមួយ លោកអ្នកយល់ថា ការសម្ងាត់របស់ខ្លួនត្រូវបានលេចធ្លាយ ក្រុមគ្រួសារកុមារអាចដាក់ពាក្យបណ្តឹងជាមួយ OCDEL បាន ដោយទូរស័ព្ទមកកាន់ 717-346-9320។